# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# នៅព្រះសហគមន៍សន្តិម៉ារីញញឹមចំការទៀន
# តាកែវ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០
# ព្រះជាម្ចាស់ត្រាស់ហៅបងប្អូនឲ្យបម្រើព្រះសហគមន៍លើទឹកដីផ្ទាល់ខ្លួន

**អត្ថបទទី១៖ កិច្ចការ ២,១៤.៣៦-៤១**

សូមបងប្អូនជ្រាប ហើយផ្ទៀងត្រចៀកស្តាប់ពាក្យរបស់ខ្ញុំ។ កក ២,១៤

**អត្ថបទទី២៖ ពេត្រុសទី១ ២,២០ខ-២៥**

ប្រសិនបើបងប្អូនបានប្រព្រឹត្តអំពើល្អ តែស៊ូទ្រាំនឹងទុក្ខលំបាក នោះមកពីព្រះជាម្ចាស់ប្រណីសន្តោសដល់បងប្អូន។ ១ពត្រ ២,២០ខ

**ដំណឹងល្អ៖ យ៉ូហាន ១០,១-១០**

អ្នកដែលចូលតាមទ្វារ ពិតជាគង្វាលរបស់ចៀម។ យហ ១០,២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងបានស្តាប់ពាក្យប្រស្នាអំពីកូនចៀមដែលដើរតាមគ្រូគង្វាល យើងដូចជាផ្កាឈូករ័ត្នដែលដើរតាមព្រះអាទិត្យ គឺព្រះជាម្ចាស់ដែលបំភ្លឺជីវិតរបស់យើង។ ពីព្រឹកយើងមើលព្រះយេស៊ូជាព្រះអាទិត្យរបស់ព្រះអង្គ ដែលកំពុងរះឡើងលើផែនដីរបស់យើង លើជីវិតរបស់យើង។ ពេញមួយថ្ងៃ យើងមានព្រះអាទិត្យរបស់ព្រះអង្គដែលបំភ្លឺជីវិតរបស់យើង ដែលណែនាំជីវិតរបស់យើងរហូតដល់ថ្ងៃលិច។ ពេលលិច ជីវិតរបស់យើងកំពុងសម្លឹងមើលព្រះជាម្ចាស់ថែមទៀត សូមទុកផ្កានេះនៅក្នុងដួងចិត្តរបស់យើង ដោយដឹងថាយើងជាអ្នកដើរតាមព្រះយេស៊ូដែលជាទ្វារដើម្បីណែនាំឲ្យយើងមានផ្លូវចេញចូល។ ព្រះយេស៊ូ ដែលជាជីវិតដើម្បីណែនាំឲ្យយើងមានផ្លូវដើរយ៉ាងច្បាស់លាស់ យើងធ្វើដំណើរជាមួយព្រះយេស៊ូពីព្រឹកដល់ល្ងាច ពីមួយថ្ងៃទៅមួយថ្ងៃពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់ ដើម្បីឃើញព្រះអាទិត្យរបស់ព្រះអង្គដ៏ភ្លឺនៅក្នុងជីវិតរបស់យើង។

សម្រាប់យុវជនយុវនារីនៅក្នុងភូមិភាគភ្នំពេញ ក៏ដូចជានៅក្នុងព្រះសហគមន៍កាតូលិកកម្ពុជា ពីមួយឆ្នាំទៅមួយឆ្នាំយើងមានទិវានៃការត្រាស់ហៅ។ យើងបានចាប់ផ្តើមពីឆ្នាំ២០១២ នៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូចជាមួយធាតុសន្តិតេរេសា រហូតដល់ឆ្នាំនេះដែលយើងត្រូវជួបគ្នាពីចម្ងាយ។ យើងជួបគ្នាពីចម្ងាយពិតមែន ប៉ុន្តែណែនាំឲ្យយើងដាក់សំណួរសម្រាប់ជីវិតរបស់យើង ខ្ញុំជឿថាពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០នេះ ដែលយើងបានបិទសាលា បិទសកម្មភាពសាសនា បិទការជួបជុំគ្នាផ្សេងៗ យើងមានពេលច្រើនដើម្បីគិតអំពីអត្ថន័យនៃជីវិត គិតអំពីតម្លៃនៃជីវិត និងគិតអំពីគោលដៅនៃជីវិតរបស់យើង។ យើងមានពេលច្រើនជាងមុន ដើម្បីថែរក្សាជីវិតរបស់យើង ថែរក្សាព្រះសហគមន៍របស់យើង។ ខ្ញុំគិតថា នៅពេលនេះយើងអាចទទួលពន្លឺថ្មីដើម្បីនឹកឃើញនៅក្នុងជីវិតរបស់យើងមានអ្វីខ្លះដែលសំខាន់។ គ្រួសារសំខាន់ណាស់ មិត្តសម្លាញ់ ការសិក្សា សុខភាព ណែនាំឲ្យយើងគិតអំពីតម្លៃនៃជីវិតរបស់យើង។ ដូច្នេះ ឲ្យយើងថែរក្សាសុខភាព

ថែរក្សាជីវិតរបស់យើងនៅពេលយើងនៅក្នុងភាពជាយុវវ័យ។ យើងយល់ថាទំនាក់ទំនងនៅក្នុងពិភពលោក ប្រហែលយើងបានបង្កើតថ្មីនៅក្នុងពេលវេលានេះ ប្រហែលយើងមិនដែលចាប់អារម្មណ៍អំពីពិភពលោកដូចសព្វថ្ងៃ។ សព្វថ្ងៃ យើងឃើញនៅក្នុងកាសែត នៅក្នុងគេហទំព័រព័ត៌មានផ្សេងៗ យើងដឹងអំពីស្ថានភាពនៅតាមប្រទេសនានាក្នុងពិភពលោក។ នេះណែនាំឲ្យយើងយល់ថា យើងមិនមែននៅម្នាក់ឯងក្នុងផ្ទះ ក្នុងភូមិយើង គឺយើងចូលនៅក្នុងពិភពលោកទាំងមូល។ ប៉ុន្តែ អ្វីដែលសំខាន់ជាងគេនោះគឺ ព្រះជាម្ចាស់ដែលជាអាទិភាពមុនគេបង្អស់ ខ្ញុំជឿថាបងប្អូនដែលកំពុងពិបាក បងប្អូនដែលកំពុងឯកោ ប្រសិនបើយើងមានតែព្រះជាម្ចាស់មួយព្រះអង្គនោះភាពឯកោបាត់អស់ហើយ តម្លៃនៃជីវិតរកឃើញអស់ហើយ។ នៅក្នុងសម័យ ប៉ុល ពត គ្រីស្តបរិស័ទជួបជុំគ្នាមិនបានទេ អត់មានការអប់រំជំនឿ អត់មានអភិបូជា បូជាចារ្យក៏ឥតមាន។ ប៉ុន្តែ គ្រីស្តបរិស័ទយើងបានតស៊ូដោយសារនឹកឃើញដល់ព្រះជាម្ចាស់ នឹកឃើញដល់ជំនឿដែលគេមាន។ គេចាំពាក្យអធិដ្ឋាន ចាំបទចម្រៀង ដោយសារគេមានជំនឿរឹងមាំ។ នេះជាពេលវេលា ដើម្បីនឹកឃើញអាទិភាពរបស់យើង ដើម្បីជម្រុញកម្លាំងរបស់យើងឲ្យយល់ថានៅក្នុងបរិយាកាសនេះ **ខ្ញុំបានរកឃើញវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតខ្ញុំ តើខ្ញុំអាចធ្វើអ្វីខ្លះសម្រាប់ព្រះជាម្ចាស់ និងព្រះសហគមន៍?**

សម្រាប់លោកបូជាចារ្យ បងប្រុសបងស្រី ឪពុកម្ដាយធម៌ ក្រុមគ្រួសារ គ្រីស្តបរិស័ទ យុវជនយុវនារីយើងប្រសិនបើគ្មានលោកឪពុក បងប្រុសបងស្រី ឪពុកម្ដាយធម៌ ក្រុមគ្រួសារ និងគ្រីស្តបរិស័ទដែលធ្វើដំណើរជាមួយពួកគាត់ ដែលលើកទឹកចិត្តពួកគាត់ ប្រហែលគេរកមិនឃើញផ្លូវទៅរកព្រះយេស៊ូផ្ទាល់បានទេ គេរកមិនឃើញខ្លោងទ្វារដើម្បីចូលតាមព្រះយេស៊ូដែលជាទ្វារបានទេ។ ដូច្នេះ ខ្ញុំជឿថាលោកបូជាចារ្យ បងប្រុសបងស្រី ឪពុកម្ដាយធម៌ ក្រុមគ្រួសារ គ្រីស្តបរិស័ទនេះជាពេលវេលាដើម្បីឲ្យយើងធ្វើដំណើរថែមទៀតជាមួយយុវជនយុវនារីរបស់យើង។ ជាពេលវេលាដើម្បីឲ្យយើងអធិដ្ឋានថែមទៀតសម្រាប់យុវជនយុវនារីយើង ជាពេលវេលាដើម្បីស្ដាប់សំណួររបស់យុវជនយុវនារីអំពីជីវិត អំពីតម្លៃនៃជីវិត អំពីបញ្ហាផ្សេងៗ ។ យុវជនយុវនារី គេត្រូវការយើងដើម្បីស្ដាប់ ដើម្បីលើកទឹកចិត្ត ដើម្បីធ្វើដំណើរជាមួយគ្នា។ នេះជាពេលវេលា ដើម្បីឲ្យយើងជាបូជាចារ្យ បងប្រុសបងស្រី ឪពុកម្ដាយធម៌ ក្រុមគ្រួសារ គ្រីស្តបរិស័ទ លើកទឹកចិត្តយុវជនយុវនារីរបស់យើង ណែនាំឲ្យយុវជនយុវនារីអាចបញ្ចេញទេពកោសល្យផ្ទាល់ខ្លួន សមត្ថភាពផ្ទាល់ខ្លួន ដើម្បីរីកចម្រើននៅក្នុងជីវិត។ ពេលយើងមានអាយុ១៥ឆ្នាំ ១៨ឆ្នាំ ២០ឆ្នាំ ២៥ឆ្នាំ យើងពោរពេញដោយសុបិន និងភាពអស់សង្ឃឹមច្រើន ប៉ុន្តែបើមានលោកបូជាចារ្យម្នាក់ បងប្រុសបងស្រីម្នាក់ ឪពុកម្ដាយធម៌ម្នាក់ ក្រុមគ្រួសារណាមួយ គ្រីស្តបរិស័ទម្នាក់ ដែលនិយាយថាប្អូនអើយប្អូនមានតម្លៃណាស់ មានសមត្ថភាពណាស់ មានកម្លាំងណាស់ សូមទៅមុខជាមួយសមត្ថភាពផ្ទាល់ខ្លួនដើម្បីធ្វើដំណើរតទៅទៀត នោះណែនាំឲ្យពួកគាត់មានកម្លាំងដើម្បីទៅមុខ។ នៅក្នុងព្រះសហគមន៍យើងមានក្រុមកាយឫទ្ធិ ក្រុមយុវជន យើងមានកន្លែងច្រើនដែលយើងអាចជួបយុវជនយុវនារី ដើម្បីធ្វើដំណើរជាមួយពួកគាត់ ដើម្បីលើកតម្កើងសមត្ថភាពរបស់គាត់។ ឲ្យសមត្ថភាពចេញ ដោយយល់ថាសមត្ថភាពនីមួយៗជាព្រះអំណោយទានដែលយើងទទួលពីព្រះជា

ម្ចាស់ផ្ទាល់ ដែលជាគ្រូគង្វាលដ៏សប្បុរស។ ប៉ុន្តែ កុំឲ្យគ្រូគង្វាលដ៏សប្បុរសទៅជាព្រះយេស៊ូនៅតែក្នុងទូព្រះកាយ ព្រះយេស៊ូនៅតែលើតុអាសន គ្រូគង្វាលដ៏សប្បុរសសព្វថ្ងៃគឺលោកបូជាចារ្យ បងប្រុសបងស្រី ឪពុកម្ដាយធម៌ ក្រុមគ្រូសារ គ្រីស្តបរិស័ទ ដែលធ្វើដំណើរជាមួយយុវជនយុវនារី ដើម្បីបង្ហាញអំពីសេចក្ដីស្រឡាញ់ ការលើកទឹកចិត្ត និងការថែទាំរបស់ព្រះយេស៊ូផ្ទាល់ដែលជាគ្រូគង្វាលណែនាំឲ្យយើងទៅមុខ។

នៅក្នុងពេលវេលាកូវីដ១៩នេះ ជាពេលវេលាដើម្បីរកឃើញអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់យើង ជាពេលវេលាដើម្បីអធិដ្ឋានថែមទៀត ជាពេលវេលាដើម្បីស្រឡាញ់ថែមទៀត ជាពេលវេលាដើម្បីទៅជាគ្រីស្តទូត។ ប្រសិនបើ យើងមើលក្រុមគ្រីស្តទូតនិងគ្រីស្តបរិស័ទពីដើម គេនឹងអធិដ្ឋាន គេនឹងស្ដាប់ការអប់រំពីក្រុមគ្រីស្តទូតអំពីព្រះបន្ទូលរបស់ព្រះយេស៊ូ គេនឹងចែករំលែកអ្វីដែលគេមានចែកដល់អ្នកក្រីក្រ ស្ត្រីមេម៉ាយ ចាស់ជរា កុមារកំព្រា និងអ្នកជំងឺ។ ជាពេលវេលា ដើម្បីឲ្យយើងភ្ញាក់ស្មារតីដោយដឹងថាព្រះជាម្ចាស់ត្រាស់ហៅប្អូនៗជាយុវជនយុវនារី ឲ្យក្រោកឈរឡើងទៅប្រកាសដំណឹងល្អអស់មួយជីវិត។ ឲ្យព្រះសហគមន៍យើងមានគ្រូគង្វាលជាច្រើន ជាបូជាចារ្យ ជាបងប្រុសបងស្រី ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ដ៏ពេញលក្ខណៈ ដែលដើរជាមួយលោកឪពុក បងប្រុសបងស្រីខ្មែរ ដែលចេះបម្រើប្រជារាស្ត្រផ្ទាល់ខ្លួន។ ព្រះសហគមន៍របស់យើង មានសាសនទូតច្រើនដែលបានមកពីប្រទេសជាច្រើន ប៉ុន្តែ យើងខ្វះបូជាចារ្យ យើងខ្វះបងប្រុសបងស្រីដែលចេញពីទឹកដីផ្ទាល់ខ្លួនដើម្បីបម្រើទឹកដីផ្ទាល់ខ្លួន។ ពេលព្រឹកយើងមើលព្រះអាទិត្យរះ ពេលល្ងាចយើងមើលព្រះអាទិត្យលិច គឺព្រះយេស៊ូផ្ទាល់ដែលកំពុងរះលើជីវិតចាស់របស់យើង ដើម្បីឲ្យយើងទៅជាមនុស្សថ្មីដែលពោរពេញដោយកម្លាំងកាយកម្លាំងចិត្ត មនុស្សថ្មីដែលថា **ខ្ញុំសុខចិត្តដើរតាមព្រះយេស៊ូ ដោយសារព្រះអង្គស្រឡាញ់ខ្ញុំនិងត្រូវការខ្ញុំដើម្បីបង្កើតព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជាយើង។**

ខ្ញុំអធិដ្ឋានដើម្បីឲ្យយើងពោរពេញដោយសេចក្ដីក្លាហាន ខ្ញុំអធិដ្ឋានដើម្បីឲ្យយើងបាត់បង់ភាពអស់កម្លាំងរបស់យើង ខ្ញុំអធិដ្ឋានដើម្បីឲ្យព្រះសហគមន៍របស់យើងអាចកោតសរសើរលើកតម្កើងព្រះជាម្ចាស់ដូចព្រះនាងម៉ារី។ នៅពេលព្រះនាងម៉ារីបានឆ្លើយថា "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**" នៅពេលនោះព្រះនាងម៉ារីបានកោតសរសើរព្រះជាម្ចាស់។ ដូច្នេះ ពេលនេះរួមជាមួយព្រះនាងម៉ារីយើងនឹងច្រៀងកោតសរសើរព្រះជាម្ចាស់ ដើម្បីឲ្យយើងជាព្រះសហគមន៍នៅប្រទេសកម្ពុជាកោតសរសើរព្រះជាម្ចាស់ ដោយសារយើងដឹងថានៅក្នុងចំណោមយើងមានយុវជនយុវនារីយ៉ាងច្រើន កំពុងត្រៀមខ្លួនដើម្បីដើរតាមព្រះយេស៊ូដែលបានត្រាស់ហៅយ៉ាងច្បាស់លាស់។ អាម៉ែន៕